## ១. តើពន្ធលើប្រាក់បៀវត្សគឺជាអ្វី?

យោងតាមមាត្រា ៤១ នៃច្បាប់ស្តីពីសារពើពន្ធ ឆ្នាំ១៩៩៧ ពន្ធលើប្រាក់បៀវត្ស គឺជាពន្ធប្រចាំខែកំណត់លើប្រាក់បៀវត្សដែលបានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញសកម្មភាពបម្រើការងារ។

និយោជក គឺជាអ្នកមានកាតព្វកិច្ចកាត់ពន្ធពីនិយោជិត នៅពេលបើកប្រាក់បៀវត្សប្រចាំខែ។ បន្ទាប់មក និយោជកត្រូវយកពន្ធនេះទៅបង់នៅសាខាពន្ធដារខេត្ត ឬខណ្ឌ យ៉ាងយូរបំផុតត្រឹមថ្ងៃទី20 នៃខែបន្ទាប់។

## ២. តើអ្វីខ្លះដែលត្រូវគិតបញ្ចូលជាប្រាក់បៀវត្សជាប់ពន្ធ?

ត្រូវរាប់បញ្ចូលជាប្រាក់បៀវត្សជាប់ពន្ធ គឺរួមមានទាំង ប្រាក់ខែ ប្រាក់បំណាច់ ប្រាក់ម៉ោងបន្ថែម ប្រាក់ប៉ះប៉ូវ និងអត្ថប្រយោជន៍បន្ថែមផ្សេងទៀត (ដូចជាការឲ្យម៉ូតូ ឬឡានទៅបុគ្គលិកប្រើប្រាស់ ការផ្តល់ធានារ៉ាប់រងសុខភាព ការផ្តល់ជំនួយសម្រាប់ការសិក្សារបស់កូន ជាដើម)។

លុយបុរេប្រទាន ឬលុយដែលនិយោជកឲ្យទៅនិយោជិតខ្ចី ក៏ត្រូវរាប់បញ្ចូលក្នុងប្រាក់បៀវត្សជាប់ពន្ធដែរ។ លុយនេះត្រូវបូកបន្ថែមលើប្រាក់បៀវត្ស នៅក្នុងខែដែលឲ្យខ្ចី ហើយកាត់បន្ថយពីប្រាក់បៀវត្ស ក្នុងខែដែលនិយោជិត បង់សងទៅនិយោជកវិញ។

### ៣. Financial Statement មានប៉ុន្មាន? មានអ្វីខ្លះ?

រួមមាន 4 គឺ

- Income Statement
- Statement of Owner's Equity
- Balance Sheet
- Statement of Cash Flow

## ៤. តើអ្នកណាខ្លះដែលច្បាប់កំណត់លើកលែងពន្ធលើប្រាក់បៀវត្ស?

យោងតាម មាត្រា ៤២ថ្មី និងមាត្រា ៤៣ នៃច្បាប់ស្តីពីសារពើពន្ធ ឆ្នាំ១៩៩៧ ប្រាក់បៀវត្សដែលត្រូវបានលើកលែងពន្ធ រួមមាន៖

- ប្រាក់បៀវត្សរបស់មន្ត្រី និងនិយោជិត នៃស្ថានទូត ឬស្ថានកុងស៊ុលបរទេស ដែលកាន់លិខិតឆ្លងដែនការ ទូត ឬលិខិតឆ្លងដែនផ្លូវការរបស់ប្រទេសនោះ

- ប្រាក់បៀវត្សរបស់មន្ត្រី និងនិយោជិតបរទេស នៃអង្គការអន្តរជាតិ ឬរបស់ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសនៃរដ្ឋាភិបាលបរទេស

- សមាជិកសភា និងសមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា។

## ៥. នៅព្រះរាជាណាចក្រកម្ពុជា តើអាករពិសេស ត្រូវយកលើមុខទំនិញ និងសេវាអ្វីខ្លះ? ដោយមូលហេតុអ្វីខ្លះ?

នៅពេលព្រះរាជាណាចក្រកម្ពុជា អាករពិសេស ត្រូវបានប្រមូលលើមុនទំនិញ និងសេវាដូចខាងក្រោម ៖

- រថយន្ត ម៉ូតូ ប្រេងឥន្ធនៈគ្រប់ប្រភេទ ឬផលិតផលតេលសេលា ស្រាបៀរ ស្រា បារី ថ្នាំជក់ គ្រឿងក្រអូប គ្រឿងសម្អាងការ ភេសជ្ជៈផ្សេងៗ សេវាលំហែកកំសាន្ត សេវាដឹកជញ្ជូនផ្លូវអាកាសសេវាទូរសព្ទ

- មូលហេតុនៃការប្រមូលអាករពិសេស គឺដើម្បីបង្កើនចំណូលលើការប្រើនប្រាស់ទំនិញ ឬសេវាដែលមានលក្ខណៈប្រណិត ឬមិនចាំបាច់ក្នុងជីវិភាពរស់នៅ ឬទំនិញដែលមានប៉ះពាល់ដល់បរិស្ថាននិងសុខភាព ។

## ៦. ប្រសិនបើអ្នកជាថ្នាក់ដឹកនាំ នៃអគ្គនាយដ្ឋានដារតើអ្នកត្រូវធ្វើដូចម្តេច ដើម្បីឱ្យចំណូលពន្ធដារកើនឡើង?

ប្រសិនជាខ្ញុំ ជាថ្នាក់ដឹកនាំនៃអគ្គនាយកពន្ធដារ ដើម្បីធ្វើឱ្យចំណូលពន្ធកើនឡើង ខ្ញុំត្រូវ ៖

- កសាងគោលនយោបាយ និងច្បាប់ស្តីពីពន្ធដារឱ្យបានល្អ

- បណ្តុះបណ្តាលមន្ត្រីពន្ធដារឱ្យមានសមត្ថភាព វិជ្ជាជីវៈ និងក្រមសីលធម៌ត្រឹមត្រូវក្នុងការផ្តល់សេវា

- អប់រំណែនាំឱ្យបានអ្នកជាប់ពន្ធ យល់ច្បាស់អំពីកាតព្វកិច្ច និងការបង់ពន្ធរបស់ខ្លួន

- ផ្តល់សេវាឱ្យបានល្អប្រសើរដល់អ្នកជាប់ពន្ធ
- ធ្វើសវនកម្ម ដើម្បីធានាភាពត្រឹមត្រូវ នៃការប្រកាសបង់ពន្ធរបស់អ្នកជាប់ពន្ធ
- ចាត់វិធានការក្តៅ ត្រជាក់ ដល់អ្នកជាប់ពន្ធដែលជាប់បំណុលពន្ធ ទូទាត់បំណុលឱ្យបានទាន់ពេល
- ចាត់វិធានការក្តៅ ត្រជាក់ ដល់អ្នកជាប់ពន្ធដែលជាប់ពន្ធគេចវេសមិនបង់ពន្ធជូនរដ្ឋ ។

**III ) Exercises**

## លំហាត់ទី១

លោក ហេង ដែលមានអគារបីជាន់ (E0 E1 និងE2) ទំហំ៤x១៦ម៉ែត្រនៃទំហំដីសរុបមាន ១០x៤០ម៉ែត្រ។ តម្លៃដីលើទីផ្សារក្នុងមួយម៉ែត្រការ៉េដែលត្រូវបានវាយតម្លៃដោយគណៈកម្មការវាយតម្លៃមានដូចខាងក្រោម៖

តម្លៃដី៖ ៤០០ ដុល្លារក្នុងមួយម៉ែត្រការ៉េ

ជាន់ផ្ទាល់ដី (E0)៖ ១២០ដុល្លារក្នុងមួយម៉ែត្រការ៉េ

ជាន់ទី១ (E1)៖ ៨០ដុល្លារ ក្នុងមួយម៉ែត្រការ៉េ

ជាន់ទី២ (E2) ៖ ៦៥ដុល្លារ ក្នុងមួយម៉ែត្រការ៉េ

គណនា ពន្ធលើអចលនទ្រព្យត្រូវបង់ប្រចាំឆ្នាំ (15 pts)

<u>ចម្លើយទី១</u>

តម្លៃដី៖ ៤០០ដុល្លារ x ៤០០ដុល្លារ = ១៦០,០០០ដុល្លារ

ជាន់ផ្ទាល់ដី (E0)៖ ៦៤ដុល្លារ x ១២០ដុល្លារ = ៧,៦៨០ដុល្លារ

ជាន់ទី១ (E1) ៦៤ដុល្លារ x ៨០ដុល្លារ = ៥,១២០ដុល្លារ

ជាន់ទី២ (E2)៖ ៦៤ដុល្លារ x ៦៥ដុល្លារ = ៤,១៦០ដុល្លារ

តម្លៃអចលនទ្រព្យសរុបគឺ៖ ១៧៦,៩៦០ដុល្លារ

ពន្ធអចលនទ្រព្យ = (៨០%នៃតម្លៃអចលនទ្រព្យ - ២៥,០០០ដុល្លារ) x 0.១%

= (១៤១,៥៦៨ដុល្លារ - ២៥,០០០ដុល្លារ)x 0,១% = ១១៦,៥ដុល្លារ

## លំហាត់ទី២

ឈ្មោះអ្នកខ្ចីប្រាក់ ឈួន ណារី ចំនួនទឹកប្រាក់ខ្ចី $3,000, រយៈពេល 180 ថ្ងៃ

អត្រាការប្រាក់ប្រចាំខែ 2%, កាលបរិច្ឆេទខ្ចីប្រាក់ 15 Jan, 2019

Required:

ចូរបំពេញតារាងបង់រំលស់ប្រាក់ដើមថេរ និងបង់ការប្រាក់លើប្រាក់ដើមដែលនៅសល់: (15 pts)

<u>ចម្លើយទី២</u>

តារាងបង់រំលស់ប្រាក់ដើមថេរ និងបង់ការប្រាក់លើប្រាក់ដើមដែលនៅសល់:

| ល,រ | កាលបរិចេទត្រូវបង់ | ទឹកប្រាក់សរុបត្រូវបង់ | ប្រាក់ដើមត្រូវបង់ | ការប្រាក់ត្រូវបង់ | ប្រាក់ដើមនៅជំពាក់ |
|---|---|---|---|---|---|
| 0 | 15-01-2019 | | | | $3000 |
| 1 | 06-02-2019 | $544.00 | $500 | $44.00 | 2500 |

| | | | | | |
|---|---|---|---|---|---|
| 2 | 06-03-2019 | 546.67 | 500 | 46.67 | 2000 |
| 3 | 08-04-2019 | 544.00 | 500 | 44.00 | 1500 |
| 4 | 08-05-2019 | 530.00 | 500 | 30.00 | 1000 |
| 5 | 12-06-2019 | 523.34 | 500 | 23.34 | 500 |
| 6 | 14-07-2019 | 510.67 | 500 | 10.67 | 0 |
| សរុប | | 3198.68 | 3000 | 198.68 | 0 |